# ការវាយតម្លៃបឋមលើផលប៉ះពាល់
# សំណើបញ្ញត្តិកម្មពាក់ព័ន្ធនឹងលក្ខណវិនិច្ឆ័យនៃប្រភេទគ្រឹះស្ថានសិក្សាចំណេះទូទៅ
# ក្រសួងអប់រំ យុវជន និងកីឡា

លេខយោង: ០១/១៨ អយក.ក.វ.ផ.ល

កាលបរិច្ឆេទចាប់ផ្តើម: ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨

កាលបរិច្ឆេទបញ្ចប់: ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

បញ្ញត្តិកម្មនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង កំណត់អំពីលក្ខណវិនិច្ឆ័យនៃប្រភេទគ្រឹះស្ថានសិក្សាចំណេះទូទៅ ។

បញ្ញត្តិកម្មនេះមានវិសាលភាពអនុវត្តគ្រប់គ្រឹះស្ថានសិក្សាចំណេះទូទៅ ទាំងសាធារណៈ និងឯកជនស្ថិតក្រោមវិសាលភាពនៃច្បាប់ស្តីពីការអប់រំ។

អនុលោមតាមច្បាប់ស្តីពីការអប់រំ និងព្រះរាជក្រឹត្យស្តីពីប្រព័ន្ធអប់រំ១២ឆ្នាំ ការអប់រំចំណេះទូទៅរួមមាន ៖ ការអប់រំបឋមសិក្សា ឬភូមិសិក្សាទី១ មាន៦ថ្នាក់ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ នៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬការអប់រំកម្រិតសមមូល ការអប់រំមធ្យមសិក្សា ឬភូមិសិក្សាទី២ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ ការអប់រំមធ្យមសិក្សាមានពីរដំណាក់កាល ដំណាក់កាលទី១ គឺមធ្យមសិក្សាបឋមភូមិ មាន៣ឆ្នាំ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ និងដំណាក់កាលទី២ គឺមធ្យមសិក្សាទុតិយភូមិ មាន៣ឆ្នាំ ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ ដោយឡែក ការអប់រំកម្រិតមត្តេយ្យសិក្សា ពុំរាប់បញ្ចូលក្នុងប្រព័ន្ធអប់រំចំណេះទូទៅឡើយ។ ការអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ហៅថាការអប់រំមូលដ្ឋាន ៩ឆ្នាំ។ បឋមសិក្សា ត្រូវបញ្ចប់ដោយការប្រឡងឡើងថ្នាក់។ មធ្យមសិក្សាបឋមភូមិ ត្រូវបញ្ចប់ដោយការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។ មធ្យមសិក្សាទុតិយភូមិ ត្រូវបញ្ចប់ដោយការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

គ្រឹះស្ថានបឋមសិក្សាមានការប្រើប្រាស់ឈ្មោះជាទូទៅថា "សាលាបឋមសិក្សា" ដែលផ្តល់សេវាអប់រំចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦។ ភូមិសិក្សាទី២ដំណាក់កាលទី១ ប្រើប្រាស់ឈ្មោះជាទូទៅថា "អនុវិទ្យាល័យ" ដែលផ្តល់សេវាអប់រំចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩។ រីឯ ភូមិសិក្សាទី២ដំណាក់កាលទី២ ប្រើប្រាស់ឈ្មោះជាទូទៅថា "វិទ្យាល័យ" ដែលផ្តល់សេវាអប់រំចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ ក្នុងស្ថានភាពជាក់ស្តែង ការប្រើប្រាស់ឈ្មោះវិទ្យាល័យ បានផ្តល់សេវាអប់រំ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។

## ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

## ផលប៉ះពាល់សំខាន់នៃសំណើបញ្ញត្តិកម្មលើវិស័យ

☐សេដ្ឋកិច្ច ☐សង្គមកិច្ច ☐បរិស្ថាន ☑អប់រំ

## ១. ការកំណត់បញ្ហា

១.ក បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

### ១.ពុំទាន់បានអនុវត្តស្របតាមស្មារតីនៃច្បាប់ស្តីពីការអប់រំត្រង់មាត្រា១២ និងមាត្រា៥៤

មាត្រា១២នៃច្បាប់ស្តីពីការអប់រំ បានកំណត់ថា "ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាទាំងអស់ ត្រូវស្របតាមបេសកកម្មអប់រំរបស់ខ្លួន។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីការកំណត់ប្រភេទគ្រឹះស្ថានសិក្សា។" មាត្រា៥៤ បានកំណត់ថា "បន្ទាប់ពីច្បាប់នេះចូលជាធរមាន ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សាណាដែលកំពុងដំណើរការខុសពីបញ្ញត្តិនៃច្បាប់នេះ ត្រូវបំពេញបែបបទឱ្យបានត្រឹមត្រូវ ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ឆ្នាំ។" តាមស្មារតីនេះ យើងឃើញថាអ្វីៗត្រូវធ្វើឱ្យបានចប់សព្វគ្រប់ក្នុងកំឡុងឆ្នាំ២០០៩ ដោយហេតុថា ច្បាប់ស្តីពីការអប់រំ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។ ប៉ុន្តែ រហូតមកដល់ពេលនេះ បញ្ញត្តិកម្មពាក់ព័ន្ធនឹងការកំណត់ប្រភេទគ្រឹះស្ថានសិក្សា មិនទាន់មាននៅឡើយទេ។

### ២.បច្ចេកសព្ទសម្រាប់ហៅឈ្មោះគ្រឹះស្ថានសិក្សាមានលក្ខណសម្បូរបែប

បច្ចុប្បន្ន គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈមាន គ្រឹះស្ថានបឋមសិក្សា ដែលប្រើប្រាស់ឈ្មោះថា "សាលាបឋមសិក្សា" ផ្តល់ការអប់រំចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៦ គ្រឹះស្ថានមធ្យមសិក្សាបឋមភូមិប្រើប្រាស់ឈ្មោះថា "អនុវិទ្យាល័យ" ផ្តល់ការអប់រំចាប់ពីថ្នាក់ទី៧ដល់ទី៩ និងគ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិ ប្រើប្រាស់ឈ្មោះថា "វិទ្យាល័យ" ផ្តល់ការអប់រំចាប់ពីថ្នាក់ទី១០ដល់ទី១២។ បន្ថែមលើនេះ យើងសង្កេតឃើញមានការប្រើប្រាស់ឈ្មោះ "វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស សាលាមធ្យមសិក្សាធនធាន និងសាលារៀនជំនាន់ថ្មី" ដែលផ្តល់សេវាអប់រំកម្រិតដូចគ្នានឹងវិទ្យាល័យដែរ គឺចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ ករណីនេះ បង្កឱ្យមានប្រតិឃាតរវាងការប្រើប្រាស់បច្ចេកសព្ទគ្រឹះស្ថានសិក្សាថ្មី និងបច្ចេកសព្ទគ្រឹះស្ថានសិក្សាចាស់ ដែលខុសពីអត្ថន័យនៃកម្រិតបណ្តុះបណ្តាលរបស់ខ្លួន និងបង្កឱ្យបាត់បង់នូវឯកភាពក្នុងការប្រើប្រាស់បច្ចេកសព្ទគ្រឹះស្ថានសិក្សា។

### ៣.ការប្រើឈ្មោះគ្រឹះស្ថានសិក្សាដែលមិនមានក្នុងប្រព័ន្ធផ្តល់ប្រាក់បំណាច់មុខងារក្នុងវិស័យអប់រំ

នៅតាមរាជធានី ខេត្ត មួយចំនួន បានរៀបចំឱ្យមានសាលារៀន ដែលផ្តល់សេវាអប់រំ ចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៩។ ការរៀបចំឱ្យមានសាលារៀនបែបនេះ ហើយដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយក០១រូប ដែលនាយកនោះទទួលប្រាក់បំណាច់មុខងារជានាយកអនុវិទ្យាល័យ ប៉ុន្តែទំហំការងារ និងការទទួលខុសត្រូវរបស់គាត់ ស្មើនឹងទំហំការងាររបស់នាយកសាលាបឋមសិក្សាបូកជាមួយនឹងទំហំការងាររបស់នាយកអនុវិទ្យាល័យ។ ករណីនេះ បានបង្ហាញឱ្យឃើញអំពីភាពផ្សេងគ្នានៃទំនួលខុសត្រូវការងារ និងលាភការដែលត្រូវទទួលបាន។ ករណីនេះទៀតសោត បានបង្កើតឱ្យមានបញ្ហាប្រឈមមួយចំនួនដូចជា ៖

ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងសម្ភារនិងទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ជាពិសេស ការរៀបចំផែនការអភិវឌ្ឍសាលារៀន។

**៤.ពុំទាន់មានគោលការណ៍ ឬលក្ខណវិនិច្ឆ័យច្បាស់លាស់សម្រាប់ដាក់ឈ្មោះ ឬហៅឈ្មោះគ្រឹះស្ថានសិក្សា**

ក្នុងការដាក់ឈ្មោះ ឬហៅឈ្មោះគ្រឹះស្ថានសិក្សា យើងពុំទាន់មានគោលការណ៍ ឬលក្ខណវិនិច្ឆ័យជាក់លាក់នៅឡើយ។ ឧទាហរណ៍ ៖ ក្នុងការហៅឈ្មោះសាលាបឋមសិក្សា តើគួរមានលក្ខណវិនិច្ឆ័យ ឬគោលការណ៍អ្វីខ្លះ សម្រាប់ដាក់ឈ្មោះ ឬហៅឈ្មោះ ដូចជា៖ ការផ្តល់សេវាអប់រំ អាយុរបស់អ្នកសិក្សា រយៈពេលបណ្តុះបណ្តាល ឬហេដ្ឋារចនាសម្ព័ន្ធជាដើម។

**៥.ភាពផ្សេងគ្នានៃការប្រើប្រាស់បច្ចេកសព្ទសម្គាល់ឈ្មោះគ្រឹះស្ថានសិក្សាចំណេះទូទៅជាក់ស្តែង និងបច្ចេកសព្ទដែលមាននៅក្នុងព្រះរាជក្រឹត្យស្តីពីប្រព័ន្ធអប់រំ១២ឆ្នាំ**

អនុលោមតាមព្រះរាជក្រឹត្យស្តីពីប្រព័ន្ធអប់រំ១២ឆ្នាំ បានកំណត់ថា ក្នុងប្រព័ន្ធអប់រំចំណេះទូទៅមាន ១២ឆ្នាំ ដែលបែងចែកតាមភូមិសិក្សា រួមមាន បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ក្នុងស្ថានភាពជាក់ស្តែង គ្រឹះស្ថានសិក្សាសាធារណៈប្រើប្រាស់ឈ្មោះ "សាលាបឋមសិក្សា" សម្រាប់សម្គាល់ការអប់រំចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦។ រីឯ "អនុវិទ្យាល័យ" សម្រាប់សម្គាល់ការអប់រំចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ និង"វិទ្យាល័យ" សម្រាប់សម្គាល់ការអប់រំចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ ពាក្យ "អនុវិទ្យាល័យ" និង "វិទ្យាល័យ" មិនមានប្រើនៅក្នុងព្រះរាជក្រឹត្យស្តីពីប្រព័ន្ធអប់រំ១២ឆ្នាំ ឡើយ។

**៦.ភាពសេរីនៃការដាក់ឈ្មោះគ្រឹះស្ថានសិក្សាឯកជន**

អនុលោមតាមច្បាប់ស្តីពីការអប់រំ និងអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន បានអនុញ្ញាតឱ្យវិស័យឯកជនបើកសាលារៀនចំណេះទូទៅឯកជន ដើម្បីរួមចំណែកជួយរដ្ឋក្នុងវិស័យអប់រំ។ បើផ្អែកតាមស្ថានភាពបច្ចុប្បន្ន យើងសង្កេតឃើញថា សាលារៀនចំណេះទូទៅឯកជនភាគច្រើន ប្រើប្រាស់ឈ្មោះជាទូទៅថា "សាលា" ដែលពុំប្រើប្រាស់បច្ចេកសព្ទដូចគ្រឹះស្ថានសិក្សាសាធារណៈរួមមាន បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យនោះទេ។ ករណីនេះបង្ហាញឱ្យឃើញអំពីភាពសេរីនៃការដាក់ឈ្មោះគ្រឹះស្ថានសិក្សាឯកជន និងកង្វះភាពយកចិត្តទុកដាក់របស់ក្រសួង ដោយពុំបានពិនិត្យដិតដល់អំពីផលប៉ះពាល់នៃការប្រើប្រាស់ឈ្មោះសាលា ក្នុងកំឡុងពេលនៃការអនុញ្ញាតបើកសាលាឯកជន។

**៧.កម្រិតនៃការបណ្តុះបណ្តាលមិនឆ្លុះបញ្ចាំងបេសកកម្មអប់រំ**

គ្រឹះស្ថានសិក្សាឯកជន មិនមានការប្រើប្រាស់ឈ្មោះសម្គាល់ការផ្តល់សេវាអប់រំច្បាស់លាស់ទេ។ គ្រឹះស្ថានសិក្សាឯកជន បានផ្តល់សេវាអប់រំចំរុះកម្រិត ដែលកម្រិតនៃការបណ្តុះបណ្តាលនោះ មិនឆ្លុះបញ្ចាំងបេសកកម្មអប់រំនិងមិនឆ្លើយតបទៅនឹងឈ្មោះដែលបានប្រើ។ គ្រឹះស្ថានសិក្សាឯកជន បានប្រើឈ្មោះថា "សាលា" ហើយបានផ្តល់សេវាអប់រំរួមគ្នា មានទាំងកម្រិតមត្តេយ្យសិក្សា កម្រិតបឋមសិក្សា កម្រិតមធ្យម

សិក្សាបឋមភូមិ កម្រិតមធ្យមសិក្សាទុតិយភូមិ ភាសាបរទេសក្រៅម៉ោងធ្វើការឬវគ្គជំនាញខ្លីៗជាដើម។ ការប្រើប្រាស់ឈ្មោះ "សាលា" ធ្វើឱ្យសាធារណៈជនពិបាកដឹងអំពីកម្រិតនៃការបណ្តុះបណ្តាលនៃគ្រឹះស្ថានសិក្សាឯកជន។

១.៤ បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផងដែរ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

**១.ទីតាំងតែមួយមានសាលាពីរនៅជាមួយគ្នា**

ដូចជាបឋមសិក្សានៅជាមួយអនុវិទ្យាល័យ អនុវិទ្យាល័យនៅជាមួយវិទ្យាល័យ។ ករណីនេះ កើតឡើងភាគច្រើនដោយសារកង្វះដីសម្រាប់សាងសង់អគារ។ ទីតាំងតែមួយមានសាលាពីរនៅជាមួយគ្នានេះ បានធ្វើឱ្យមានបញ្ហាប្រឈមដូចជា ៖ បញ្ហាម៉ោងសិក្សាខុសគ្នា (ម៉ោងចេញលេងនិងចូលរៀន កាលបរិច្ឆេទវិស្សមកាល...) ដែលជះឥទ្ធិពលដល់សតិអារម្មណ៍របស់សិស្សក្នុងការរៀន ការដើរឆ្លងគ្នារបស់សិស្សបានធ្វើឱ្យគណៈគ្រប់គ្រងសាលាពិបាកក្នុងការគ្រប់គ្រងនិងតាមដានសិស្ស ការសម្អាតនិងថែរក្សាបរិស្ថានសាលារៀន ភាពជាកម្មសិទ្ធិលើការគ្រប់គ្រងទីតាំង និងការកសាងផែនការនិងអភិវឌ្ឍសាលារៀន។

**២.គ្រឹះស្ថានសិក្សាចំណោះទូទៅសាធារណៈមួយចំនួន ពុំទាន់មានប្រកាសទទួលស្គាល់ឬប្រកាសស្តីពីការបង្កើត**

ករណីនេះ កើតឡើងដោយសារតែគ្រឹះស្ថានសិក្សាទាំងនោះ បង្កើតមុនច្បាប់កំណត់ ភាពមិនច្បាស់លាស់ពីម្ចាស់កម្មសិទ្ធិលើដី គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាមួយចំនួនមិនទាន់បានយល់ដឹងអំពីនីតិវិធី និងសារៈប្រយោជន៍នៃការស្នើសុំប្រកាសទទួលស្គាល់ ឬការបង្កើត។ ករណីនេះ ធ្វើឱ្យគ្រឹះស្ថានសិក្សាមានផលលំបាកក្នុងការបើកគណនីនៅធនាគារ ព្រោះគ្រឹះស្ថានធនាគារទាំងនោះ ទាមទារប្រកាសទទួលស្គាល់ឬប្រកាសស្តីពីការបង្កើត។ ដូចនេះ ដើម្បីបើកគណនីនៅធនាគារបាន គ្រឹះស្ថានសិក្សា ត្រូវសុំលិខិតបញ្ជាក់ពីមន្ទីរ។

**៣.កង្វះហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវ័ន្ត**

នៅតាមគ្រឹះស្ថានសិក្សាសាធារណៈភាគច្រើន នៅកង្វះហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវ័ន្ត ដែលរួមមានដូចជា ៖ បន្ទប់ពិសោធន៍ កន្លែងដាក់សម្រាម អាងស្តុកទឹក សួនច្បារ សួនជីវៈចម្រុះ។ល។ ជាពិសេសបន្ទប់ទឹក បង្គន់អនាម័យ នៅមិនទាន់មានភាពល្អប្រសើរ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អ្នកសិក្សានិងបុគ្គលិកអប់រំនៅឡើយ។ ដោយឡែក សម្រាប់គ្រឹះស្ថានសិក្សាឯកជនវិញ នៅមិនទាន់ឆ្លើយតបទៅនឹងការកំណត់របស់លិខិតបទដ្ឋានគតិយុត្ត ដូចជា ៖ មិនទាន់មានសួនច្បារ សួនជីវចម្រុះ ទីលានហាត់កីឡា ចំណត ដើមឈើ ច្បាស់លាស់នៅឡើយ។ ម្យ៉ាងវិញទៀត ទំហំបន្ទប់នៃគ្រឹះស្ថានសិក្សាឯកជនភាគច្រើនមិនទាន់ឆ្លើយតបទៅនឹងទំហំបន្ទប់ដែលលិខិតបទដ្ឋានគតិយុត្តកំណត់ ដែលបន្ទប់នីមួយៗត្រូវមានទំហំ ១,៥០ ម៉ែត្រក្រឡា សម្រាប់សិស្សម្នាក់។

១.គ សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។

ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះ មិនទាន់គ្រប់គ្រាន់?

- ច្បាប់ ស្តីពីការអប់រំឆ្នាំ២០០៧
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ១២ឆ្នាំ
- អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃ១០ ខែកញ្ញា ឆ្នាំ១៩៩២ ស្តីពីអនាម័យសិក្សា
- ប្រកាសលេខ ២៩៩១ អយក.ប្រក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ
- ប្រកាសលេខ ១២៥៨ អយក.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ
- ប្រកាសលេខ ២៧៨៦ អយក.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ
- សេចក្តីណែនាំលេខ ៣៣ អយក.សណន ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ។

លិខិតបទដ្ឋានខាងលើនេះ ពុំទាន់មានចែងអំពីការប្រើប្រាស់ឈ្មោះសម្គាល់ប្រភេទគ្រឹះស្ថានសិក្សាចំណេះទូទៅ និងលក្ខណវិនិច្ឆ័យនៅឡើយ ។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំលិខិតបទដ្ឋានថ្មី សម្រាប់កំណត់លក្ខណៈវិនិច្ឆ័យនៃប្រភេទគ្រឹះស្ថានសិក្សាចំណេះទូទៅ ស្របតាមស្មារតីនៃមាត្រា ១២ នៃច្បាប់ស្តីពីការអប់រំ។

១.ឃ តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ? (ប្រសិនបើមានសូមពន្យល់)

សំណើបញ្ញត្តិកម្មនេះ មានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងជាមួយគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន។

## ២. គោលបំណង តើយើងចង់សម្រេចបានអ្វី?

សំណើបញ្ញត្តិកម្មនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងកំណត់ប្រភេទគ្រឹះស្ថានសិក្សាចំណេះទូទៅ ឱ្យបានជាក់លាក់ សំដៅពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅ និងលើកកម្ពស់ការរៀបចំនិងប្រើប្រាស់ឈ្មោះ ឱ្យស្របនឹងបេសកកម្មអប់រំរបស់គ្រឹះស្ថានសិក្សាចំណេះទូទៅទាំងសាធារណៈ និងឯកជន។

## ៣. ជម្រើស

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់)

| |
|---|
| ១.រក្សាស្ថានភាពដើម<br>២.សំណើប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់តែគ្រឹះស្ថានចំណេះទូទៅសាធារណៈ<br>៣.សំណើប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់ទាំងគ្រឹះស្ថានចំណេះទូទៅសាធារណៈ និងឯកជន។ |

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគព្វកិច្ច និងផលចំណេញ

៤.១ ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម | - គ្មាន | - គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់តែគ្រឹះស្ថានចំណេះទូទៅសាធារណៈ | - បន្ទុកចំណាយលើការរៀបចំប្រកាស ប្រហែល **១ ០៧៧ ៤៤២** រៀល<br>- បន្ទុកចំណាយលើការពិគ្រោះយោបល់ **៧២ ៩០៧ ២០០** រៀល<br>- បន្ទុកចំណាយក្នុងការផ្លាស់ប្តូរឈ្មោះ<br>- បន្ទុកចំណាយក្នុងការផ្លាស់ប្តូរត្រា<br>- បន្ទុកចំណាយក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវ័ន្ត | |
| ជម្រើសទី៣៖ សេចក្តីព្រាងប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់ទាំងគ្រឹះស្ថានចំណេះទូទៅសាធារណៈនិងឯកជន។ | - បន្ទុកចំណាយលើការរៀបចំប្រកាស ប្រហែល **១ ០៧៧ ៤៤២** រៀល<br>- បន្ទុកចំណាយលើការពិគ្រោះយោបល់ **៧២ ៩០៧ ២០០** រៀល<br>- បន្ទុកចំណាយក្នុងការផ្លាស់ប្តូរឈ្មោះ | - បន្ទុកចំណាយក្នុងការផ្លាស់ប្តូរឈ្មោះ<br>- បន្ទុកចំណាយក្នុងការផ្លាស់ប្តូរត្រា<br>- បន្ទុកចំណាយក្នុងការរៀបចំឯកសណ្ឋានសិស្ស<br>- បន្ទុកចំណាយក្នុងការផ្សព្វផ្សាយ |

| | | |
|---|---|---|
| | - បន្ទុកចំណាយក្នុងការផ្លាស់ប្តូរគ្រា<br>- បន្ទុកចំណាយក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្ត | |

៤.២ ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម | - រក្សាស្ថានភាពដើម<br>- ផលចំណេញបានតិចតួច<br>- ពុំបង្កើនបន្ទុកចំណាយក្នុងការរៀបចំបញ្ញត្តិកម្មថ្មី | - គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់តែគ្រឹះស្ថានចំណេះទូទៅសាធារណៈ | - សាធារណៈមតិមានភាពងាយស្រួលយល់និងដឹងអំពីឈ្មោះ និងបេសកកម្មរបស់គ្រឹះស្ថានសិក្សា<br>- ភាពស្រពិចស្រពិលលើលក្ខណវិនិច្ឆ័យនៃប្រភេទគ្រឹះស្ថានសិក្សាសាធារណៈត្រូវបានលុបបំបាត់<br>- មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកសិក្សាកាន់តែមានទំនុកចិត្តក្នុងការទទួលសេវាអប់រំ<br>- ប្រសិទ្ធភាពក្នុងការគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវបានលើកកម្ពស់<br>- មានឱកាសក្នុងការកៀរគរធនធានពីសប្បុរសជននានាដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា | - គ្មាន |

| | | |
|---|---|---|
| | - ផ្តល់នូវភាពជាគំរូសម្រាប់ឈានឆ្ពោះទៅការគ្រប់គ្រងប្រភេទគ្រឹះស្ថានសិក្សាឯកជន<br>- បង្ហាញឱ្យឃើញនូវឯកភាពជាតិក្នុងវិស័យអប់រំ ជាពិសេសស្មារតីច្បាប់ស្តីពីការអប់រំ ត្រង់មាត្រា១២ និងមាត្រា៥៤ ត្រូវបានអនុវត្ត | |
| ជម្រើសទី៣៖ សេចក្តីព្រាងប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់ទាំងគ្រឹះស្ថានចំណេះទូទៅ<br>សាធារណៈនិងឯកជន។ | - សាធារណៈមតិមានភាពងាយស្រួលយល់និងដឹងអំពីឈ្មោះ និងបេសកកម្មរបស់គ្រឹះស្ថានសិក្សា<br>- ភាពស្រពិចស្រពិលលើលក្ខណវិនិច្ឆ័យនៃប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវបានលុបបំបាត់<br>- មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកសិក្សាកាន់តែមានទំនុកចិត្តក្នុងការទទួលសេវាអប់រំ<br>- ប្រសិទ្ធភាពក្នុងការគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវបានលើកកម្ពស់<br>- មានឱកាសក្នុងការកៀរគរធនធានពីសប្បុរសជននានាដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា<br>- ផ្តល់នូវភាពជាគំរូសម្រាប់ឈានឆ្ពោះទៅការគ្រប់គ្រងប្រភេទគ្រឹះស្ថានសិក្សាឯកជន<br>- បង្ហាញឱ្យឃើញនូវឯកភាពជាតិក្នុងវិស័យអប់រំ ជាពិសេសស្មារតីច្បាប់ស្តីពីការអប់រំ ត្រង់ | - សាធារណៈមតិមានភាពងាយស្រួលយល់និងដឹងអំពីឈ្មោះ និងបេសកកម្មរបស់គ្រឹះស្ថានសិក្សា<br>- ភាពស្រពិចស្រពិលលើលក្ខណវិនិច្ឆ័យនៃប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវបានលុបបំបាត់<br>- មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកសិក្សាកាន់តែមានទំនុកចិត្តក្នុងការទទួលសេវាអប់រំ<br>- ប្រសិទ្ធភាពក្នុងការគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវបានលើកកម្ពស់<br>- មានឱកាសក្នុងការកៀរគរធនធានពីសប្បុរសជននានាដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា<br>- បង្ហាញឱ្យឃើញនូវឯកភាពជាតិក្នុងវិស័យអប់រំ ជាពិសេស ស្មារតីច្បាប់ស្តីពីការអប់រំ ត្រង់មាត្រា១២ និងមាត្រា៥៤ ត្រូវបានអនុវត្ត |

| | | |
|---|---|---|
| | មាត្រា១២ និងមាត្រា៥៤ ត្រូវបានអនុវត្ត | |

៤.៣ វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម | គ្មាន | គ្មាន | |
| ជម្រើសទី២៖ សេចក្តីព្រាងប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់តែគ្រឹះស្ថានចំណេះទូទៅសាធារណៈ | -បឋមសិក្សា = **៧ ១៨៩**<br>-អនុវិទ្យាល័យ = **១២៣៧**<br>-វិទ្យាល័យ = **៥១៦** | គ្មាន | សន្និបាតអប់រំឆ្នាំ២០១៦-២០១៧ |
| ជម្រើសទី៣៖ សេចក្តីព្រាងប្រកាសថ្មី ដែលមានវិសាលភាពគ្របដណ្តប់ទាំងគ្រឹះស្ថានចំណេះទូទៅសាធារណៈនិងឯកជន។ | -បឋមសិក្សា = **៧ ១៨៩**<br>-អនុវិទ្យាល័យ = **១ ២៣៧**<br>-វិទ្យាល័យ = **៥១៦** | -បឋមសិក្សា = **៤៣២**<br>-អនុវិទ្យាល័យ = **៦៦**<br>-វិទ្យាល័យ = **១២២** | សន្និបាតអប់រំឆ្នាំ២០១៦-២០១៧ |

## ៥. កិច្ចពិគ្រោះយោបល់

- បានចុះសិក្សាផលប៉ះពាល់ជាមួយមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា ចំនួន ១១ ខេត្ត សរុបមានអ្នកចូលរួមប្រមាណ ៥៨១ រូប។

## ៦. សន្និដ្ឋាន

តើចាំបាច់ធ្វើ RIS ដែរឬទេ?

☐ចាំបាច់

☑មិនចាំបាច់

| |
|---|
| បញ្ញត្តិកម្មដែលស្នើឡើងនេះ មានផលប៉ះពាល់ដល់គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន។ ទោះជាបែបណាក្តីក៏រាជរដ្ឋាភិបាល គួរតែមានវិធានការឱ្យបានច្បាស់លាស់ក្នុងការគ្រប់គ្រង និងប្រើប្រាស់ប្រភេទគ្រឹះស្ថានសិក្សាទាំងសាធារណៈ និងឯកជន។ ដូច្នេះ **ជម្រើសទី៣** គួរត្រូវបានជ្រើសរើស។ |

## ៧. ការអនុវត្តនិងការតាមដានត្រួតពិនិត្យ

៧.១តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| វិធានការដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ គឺការកំណត់រយៈពេលសមស្រប ដើម្បីឱ្យគ្រឹះស្ថានសិក្សាដែលកំពុងដំណើរការ តែមិនគោរពតាមលក្ខណវិនិច្ឆ័យកំណត់ អាចអនុវត្តឱ្យស្របតាមខ្លឹមសារនៃបទប្បញ្ញត្តិថ្មី និងពង្រឹងយន្តការនៃការបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនថ្មី។ |

៧.២តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះ គួរត្រូវបានពិនិត្យឡើងវិញ/តាមដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| ក្នុងករណីសំណើប្រកាសថ្មីត្រូវបានជ្រើសរើស ប្រកាសថ្មីនេះគួរត្រូវបានពិនិត្យឡើងវិញរៀងរាល់ ០៥ឆ្នាំម្តង។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា |
|---|---|---|---|
| រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា (ក្រុមការងារ RIA និងការិ.វាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋាន) | ឯឧ. ស៊ន សេងហុក | ប្រធានRIA | |
| | លោក ប៉ូវ វី | អនុប្រធាន RIA | |
| | ល.ស ខូវ សោភ័ណ | សមាជិកក្រុមការងារRIA | |
| | លោក រស់ ស៊ីធាន់ | អនុប្រធានការិ.វ.ផ.ល | |
| | លោក សៅ បូរិន | បុគ្គលិកអប់រំការិ.វ.ផ.ល | |
| | លោក ស៊ាន បញ្ញា | សមាជិក RIA | |
| | លោក គូ សុជាត | បុគ្គលិកអប់រំការិ.វ.ផ.ល | |
| ផ្តល់យោបល់ដោយក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត | ឯឧ. ប៊ុច សុខា | អនុប្រធានអចិន្ត្រៃយ៍ RET | |
| | ឯឧ. អេង រត្នមន្នី | ប្រធានផ្នែកបណ្តុះបណ្តាល | |